# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ចនៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍ នៅត្រីមាសទី៣ ឆ្នាំ២០១៦។

ផសស ពិត នៅឥណ្ឌូនេស៊ីកើន ៥,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ឬ ០,២ ទាបជាងកំណើននៅត្រីមាសទី២។ ការធ្លាក់ចុះនេះ អាចបណ្តាលពីការកាត់បន្ថយចំណាយរដ្ឋាភិបាល និងការថយចុះទំនិញនាំចេញ។ ម៉ាឡេស៊ីមានអត្រាកំណើន ៤,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន គឺទាបជាងអត្រាកំណើន ៤,០% កាលពីត្រីមាសទី២ ព្រោះមានតម្រូវការក្នុងស្រុកខ្លាំងជួយជំរុញ។ វិស័យសេវាកម្ម និងផលិតកម្ម ក៏បន្តរីកធំដែរក្នុងត្រីមាសទី៣ នេះ។ អត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរី ធ្លាក់ចុះមកត្រឹម ១,១% ធៀបនឹង ២,១% ក្នុងត្រីមាសមុន ព្រោះសេដ្ឋកិច្ចពិភពលោកនៅតែបង្កក្តីបារម្ភ។ សេដ្ឋកិច្ចថៃកើន ៣,២% ឬ ០,៣ ឯកតាភាគរយទាបជាងក្នុង ត្រីមាសមុន ហើយក្នុងពេលជាមួយគ្នា ចំណាយប្រើប្រាស់ឯកជនកើនឡើង រីឯទេសចរណ៍ក៏កាន់តែមានភាពប្រកួតប្រជែងខ្លាំងដែរ។ កំណើននៅវៀតណាមឡើងដល់ ៦,៤% ដែលជំរុញឡើងដោយសារចំណាយប្រើប្រាស់ឯកជន និងវិនិយោគខាងផ្នែកអេឡិចត្រូនិក។

សេដ្ឋកិច្ចប្រទេសចិនរីកលូតលាស់តាមអត្រាថេរ ៦,៧% ក្នុង ៣ ត្រីមាសដើមឆ្នាំ២០១៦ ដែលជំរុញឡើងដោយសារ សកម្មភាពសាងសង់ឡើងវិញក្រោយពេលមានទឹកជំនន់ ទីផ្សារអចលនទ្រព្យ និងចំណាយប្រើប្រាស់ឯកជន។ សេដ្ឋកិច្ចក្រុងហុងកុងកើន ១,៣% នៅត្រីមាសទី៣ ធៀបនឹង ១,៧% នៅត្រីមាសមុន។ កំណើននៅកូរ៉េខាងត្បូង ឡើងដល់ ២,៣% ឬ ០,៩ ឯកតាភាគរយទាបជាងក្នុងត្រីមាសមុន។ ផសស នៅតៃវ៉ាន់ កើន ២,០% ដែលជាកំណើនខ្ពស់បំផុត គិតតាំងពីត្រីមាសទី២ ឆ្នាំ២០១៥ មក។

កំណើន ផសស ពិតក្នុងតំបន់អឺរ៉ូ ឡើងដល់ ១,៧% ធៀបនឹង ១,៦% កាលពីត្រីមាសមុន ។ សេដ្ឋកិច្ចជប៉ុនមានកំណើន ១,១% ដែលជាកំណើនខ្ពស់បំផុតគិតតាំងពីត្រីមាសទី២ឆ្នាំ២០១៤មក។ កំណើនធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន នៅសហរដ្ឋអាមេរិក មានកម្រិត ១,៣% ដោយសារ វិនិយោគជាប់លាប់របស់អនិវាសជន ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ចំណាយរបស់រដ្ឋាភិបាល បានកើនឡើងច្រើន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

ប្រទេសទាំងអស់ក្នុងអាស៊ាន និងក្នុងតំបន់អាស៊ី មានអតិផរណា លើកលែងតែ សិង្ហបុរី និង ជប៉ុន។ អតិផរណា មានកម្រិត ៣,០% នៅកម្ពុជា ៣,០% នៅឥណ្ឌូនេស៊ី ០,៣% នៅថៃ និង ២,៨% នៅវៀតណាម។ វាមានត្រឹម ០,៣% នៅតំបន់អឺរ៉ូ ១,១% នៅសហរដ្ឋអាមេរិក រីឯ សិង្ហបុរីមានបរិត្តផរណា ១,៥%។

អតិផរណាមានកម្រិត ១,៧% នៅចិន ៣,១% នៅហុងកុង ០,៨% នៅកូរ៉េខាងត្បូង និង ០,៧% នៅតៃវ៉ាន់។ វាមានកម្រិត ០,៣% នៅតំបន់អឺរ៉ូ ១,១% នៅសហរដ្ឋអាមេរិក រីឯជប៉ុនមានបរិត្តផរណា ០,៥%។

នៅត្រីមាសទី៣ ឆ្នាំ២០១៦ ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលធ្លាក់ថ្លៃ ០,៩% ធៀបនឹងត្រីមាសមុន មកត្រឹម ៤០៩៤,១រៀល/ដុល្លារ។ ប្រាក់បាតថៃឡើងថ្លៃ ១,២% ធៀបនឹងត្រីមាសមុន ប្រាក់ដុងវៀតណាមឡើងថ្លៃ ០,១% ប្រាក់យ៉ន់ចិន ចុះថ្លៃ ២,០% ហើយ ប្រាក់យ៉េនជប៉ុនឡើងថ្លៃ ៥,៤%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ ថ្លៃទំនិញសំខាន់ៗនៅលើទីផ្សារពិភពលោក បានចុះថ្លៃ ធៀបនឹងត្រីមាសមុន លើកលែងតែផលិតផលមួយចំនួនតូច។ ពោតចុះថ្លៃ ១១,៥% ដល់ ១៥៣,៥ដុល្លារ/តោន កៅស៊ូចុះថ្លៃ ៤,៣% ដល់ ១៣៤៩,៤ដុល្លារ/តោន អង្ករចុះថ្លៃ ១,១% ដល់ ៤៣០,៣ដុល្លារ/តោន សណ្តែកសៀងចុះថ្លៃ ១,៨% ដល់៤១៦,៧ដុល្លារ/តោនសាំងចុះថ្លៃ១,៩%ដល់០,៣៦៨ដុល្លារ/លីត្រ ហើយប្រេងឆៅចុះថ្លៃ ៣,២% ដល់ ៤៣,៣ដុល្លារ/ធុង។ ប្រេងដូងប្រេងឡើងថ្លៃ ១,៥% ដល់ ៧១៤,៧ដុល្លារ/តោន ម៉ាសូតឡើងថ្លៃ ២,១% ដល់ ០,៣៦៣ដុល្លារ/លីត្រ។

---

អត្ថបទនេះ រៀបរាងដោយលោក វ៉ើន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៦ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 4.7 | 4.7 | 4.7 | 5.0 | 4.9 | 5.2 | 5.0 |
| ម៉ាឡេស៊ី | 9.0 | 4.9 | 5.4 | 4.6 | 6.0 | 5.6 | 4.9 | 4.7 | 4.5 | 4.2 | 4.0 | 4.3 |
| សិង្ហបុរី | 14.7 | 4.7 | 1.3 | 3.8 | 3.0 | 2.6 | 1.8 | 1.9 | 1.8 | 1.8 | 2.1 | 1.1 |
| ថៃ | 7.9 | 0.0 | 6.7 | 2.8 | 1.6 | 3.3 | 2.2 | 2.9 | 2.8 | 3.2 | 3.5 | 3.2 |
| វៀតណាម | 6.4 | 6.2 | 5.2 | 5.4 | 5.9 | 6.1 | 6.5 | 6.8 | 7.0 | 5.5 | 3.5 | 6.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 10.4 | 9.3 | 7.7 | 7.7 | 7.3 | 7.1 | 7.0 | 6.9 | 6.8 | 6.7 | 6.7 | 6.7 |
| ហុងកុង | 6.9 | 4.9 | 2.9 | 3.0 | 2.3 | 2.1 | 2.8 | 2.3 | 1.9 | 0.8 | 1.7 | 1.3 |
| កូរ៉េខាងត្បូង | 6.1 | 3.6 | 2.1 | 2.8 | 3.4 | 2.4 | 2.2 | 2.7 | 3.0 | 2.7 | 3.2 | 2.3 |
| តៃវ៉ាន់ | 11.1 | 4.2 | 1.2 | 2.2 | 3.5 | 3.4 | 0.5 | -1.0 | -0.5 | -0.8 | 0.7 | 2.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.6 | 1.6 | -0.5 | 0.1 | 0.7 | 1.0 | 1.2 | 1.6 | 1.5 | 1.5 | 1.6 | 1.7 |
| ជប៉ុន | 4.1 | -0.8 | 1.7 | 1.7 | 0.6 | -0.9 | 0.7 | 1.0 | 0.5 | 0.2 | 0.8 | 1.1 |
| សហរដ្ឋអាមេរិក | 2.7 | 1.8 | 2.1 | 1.8 | 2.4 | 2.7 | 2.3 | 2.2 | 1.8 | 2.1 | 1.2 | 1.3 |

Sources: International Monetary Fund, Economist and countries' statistics offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៦ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.1 | 5.5 | 3.0 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.4 | 3.1 | 3.0 |
| ឥណ្ឌូនេស៊ី | 5.1 | 5.4 | 4.3 | 7.0 | 6.4 | 6.6 | 7.1 | 7.1 | 4.8 | 4.3 | 3.5 | 3.0 |
| ម៉ាឡេស៊ី | 1.7 | 3.2 | 1.7 | 2.1 | 3.2 | 0.7 | 2.1 | 3.0 | 2.6 | 3.4 | 1.9 | 1.4 |
| សិង្ហបុរី | 2.9 | 5.2 | 4.6 | 2.3 | 1.0 | -0.3 | -0.4 | -0.6 | -0.7 | -0.8 | -0.9 | -1.5 |
| ថៃ | 3.1 | 3.8 | 3.0 | 2.2 | 1.9 | -0.5 | -1.1 | -1.1 | -0.9 | -0.5 | 0.3 | 0.3 |
| វៀតណាម | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 0.7 | 1.0 | 0.5 | 0.3 | 1.3 | 2.2 | 2.8 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 3.2 | 5.4 | 2.7 | 2.6 | 2.0 | 1.2 | 1.4 | 1.7 | 1.5 | 2.1 | 2.1 | 1.7 |
| ហុងកុង | 2.4 | 5.3 | 4.1 | 4.0 | 4.4 | 4.4 | 3.1 | 2.3 | 2.4 | 2.9 | 2.6 | 3.1 |
| កូរ៉េខាងត្បូង | 3.0 | 4.4 | 2.1 | 1.1 | 1.3 | 0.6 | 0.5 | 0.6 | 1.1 | 0.2 | 0.9 | 0.8 |
| តៃវ៉ាន់ | 1.0 | 1.4 | 1.9 | 0.8 | 1.5 | 2.9 | -0.7 | 0.0 | 0.3 | 1.7 | 1.3 | 0.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.6 | 2.7 | 2.5 | 1.4 | 0.4 | -0.3 | 0.2 | 0.0 | 0.3 | 0.1 | 0.2 | 0.3 |
| ជប៉ុន | -0.7 | 0.1 | -0.03 | 0.4 | 2.8 | 2.3 | 0.5 | 0.2 | 0.7 | 0.2 | -0.4 | -0.5 |
| សហរដ្ឋអាមេរិក | 1.7 | 3.2 | 2.1 | 1.5 | 1.6 | -0.4 | 0.0 | 0.1 | 0.4 | 1.1 | 0.7 | 1.1 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០១០-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4187.1 | 4063.6 | 4037.8 | 4027.2 | 4037.6 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 | 4056.3 | 4094.1 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9089.9 | 8748.0 | 9363.0 | 10419.2 | 11850.2 | 12809.9 | 13125.2 | 13858.0 | 13786.3 | 13627.3 | 13324.1 | 13136.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.2 | 3.1 | 3.1 | 3.1 | 3.3 | 3.6 | 3.7 | 4.1 | 4.3 | 4.2 | 4.0 | 4.0 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.3 | 1.2 | 1.3 | 1.3 | 1.4 | 1.3 | 1.4 | 1.4 | 1.4 | 1.4 | 1.4 |
| ថៃ (បាត) | 31.7 | 30.5 | 31.1 | 30.7 | 32.5 | 32.6 | 33.2 | 35.2 | 35.8 | 35.6 | 35.3 | 34.8 |
| វៀតណាម (ដុង) | 19200.8 | 20574.3 | 20856.9 | 20990.3 | 21138.2 | 21372.9 | 21712.7 | 22164.6 | 22420.7 | 22929.4 | 22314.5 | 22292.2 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.8 | 6.5 | 6.3 | 6.1 | 6.2 | 6.2 | 6.2 | 6.3 | 6.4 | 6.5 | 6.5 | 6.7 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1156.3 | 1108.6 | 1126.6 | 1095.0 | 1053.6 | 1101.7 | 1097.4 | 1170.0 | 1158.3 | 1200.8 | 1163.4 | 1120.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.5 | 29.4 | 29.6 | 29.7 | 30.3 | 31.6 | 30.8 | 32.0 | 32.6 | 33.1 | 32.4 | 31.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 0.8 | 0.8 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 | 0.9 |
| ជប៉ុន (យ៉េន) | 87.8 | 79.9 | 79.8 | 97.6 | 105.9 | 119.2 | 121.4 | 122.2 | 121.4 | 115.3 | 107.9 | 102.4 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០១០-២០១៦ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ពោត (US No.2) - (USD/តោន) | 185.9 | 291.7 | 298.4 | 259.4 | 192.9 | 174.2 | 168.4 | 169.5 | 167.1 | 160.0 | 171.1 | 153.5 |
| ប្រេងដូងប្រេង - អឺរ៉ុបពាយព្យ (USD/តោន) | 900.8 | 1125.4 | 999.3 | 856.9 | 821.4 | 627.9 | 664.0 | 514.6 | 518.0 | 586.9 | 647.8 | 714.7 |
| កៅស៊ូ SMR 5 USD/តោន) | 3405.7 | 4630.6 | 3200.7 | 2575.3 | 1755.6 | 1450.2 | 1525.9 | 1365.5 | 1229.1 | 1190.0 | 1408.1 | 1349.4 |
| អង្ករ (Thai 100% B) - បាងកក (USD/តោន) | 506.6 | 558.5 | 594.8 | 533.8 | 434.9 | 426.0 | 396.3 | 383.3 | 376.3 | 385.3 | 465.0 | 430.3 |
| សណ្តែកសៀង (US No.1) - USA (USD/តោន) | 449.8 | 540.7 | 591.4 | 538.4 | 491.8 | 363.9 | 393.7 | 347.6 | 358.0 | 328.0 | 418.7 | 416.7 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 76.8 | 106.2 | 109.5 | 105.9 | 96.2 | 50.9 | 60.5 | 48.2 | 38.0 | 31.2 | 44.7 | 43.3 |
| សាំង - US Gulf Coast (សេន/លីត្រ) | 53.3 | 71.9 | 74.6 | 71.2 | 65.6 | 40.1 | 49.0 | 42.2 | 32.9 | 27.9 | 37.5 | 36.8 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 56.1 | 75.7 | 80.7 | 78.4 | 71.5 | 44.6 | 48.4 | 39.9 | 34.0 | 27.2 | 35.6 | 36.3 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៣ ឆ្នាំ២០១៦ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ កើនដល់ ៩៥៥,៥លានដុល្លារ ឬកើន ១៥% ធៀបនឹង ត្រីមាសមុន ដែលមានត្រឹម ៨៣១,២លានដុល្លារ ឬកើន ២៤២,០% ធៀបនឹងកាលពីមួយឆ្នាំមុន។ អនុម័តវិនិយោគខាងកសិកម្ម មាន ៧,៤លានដុល្លារ ធៀបនឹង សូន្យ ក្នុងត្រីមាសទី២។ អនុមតិវិនិយោគក្នុងផ្នែកកាត់ដេរ មាន ៥១,១លានដុល្លារ គឺទាបជាខ្លាំងជាងត្រីមាសមុនដែលមានដល់ ២៣៩,៩លានដុល្លារ។ អនុមតិវិនិយោគក្នុងផ្នែកសណ្ឋាគារ និងទេសចរណ៍ កើនដល់ ៦៧៩,៨លានដុល្លារ ធៀបនឹង ១៩,៨លានដុល្លារកាលពីត្រីមាសមុន។

នៅត្រីមាសទី៣ នេះដែរ ចំនួនទេសចរអន្តរជាតិមកដល់សរុប កើន ២,៨% ធៀបនឹងត្រីមាសមុន ឬកើន ៩,៨% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១១៤៧ពាន់នាក់។ ភ្ញៀវមកដល់តាមផ្លូវអាកាស កើន ១,៥% ធៀបនឹងត្រីមាសមុន ដល់ ៦០២ពាន់នាក់ រីឯភ្ញៀវមកដល់តាមផ្លូវគោក និងផ្លូវទឹក កើន ៤,៣% ដល់ ៥៤៥ពាន់នាក់។

នៅត្រីមាសទី៣ ឆ្នាំ២០១៦ ការនាំចេញសរុប កើន ១៨,២% ធៀបត្រីមាសមុន ឬកើន ៨,៦% ធៀបមួយឆ្នាំមុន ដល់ ២៨១៧,៧លានដុល្លារ។ ការនាំចេញសម្លៀកបំពាក់ កើន ២០,៦% ធៀបត្រីមាសមុន ឬកើន ៣,៩% ធៀបមួយឆ្នាំមុន ដល់ ២០៧២,៥លានដុល្លារ។ ការនាំចេញសម្លៀកបំពាក់ទៅសហរដ្ឋអាមេរិក មានចំនួន ៥៥៤,៥លានដុល្លារ ទៅសហភាពអឺរ៉ុប មាន ៧៣៣,៣លានដុល្លារ ទៅបណ្តាប្រទេសអាស៊ាន ២១,៤លានដុល្លារ ទៅជប៉ុន ២១៦,០លានដុល្លារ និងទៅប្រទេសផ្សេងទៀត ៥៤៧,១លានដុល្លារ។ ការនាំចេញផលិតផលកសិកម្ម កើន ១៩,៤% ធៀបត្រីមាសមុន ឬកើន ៦,០% ធៀបមួយឆ្នាំមុន ដល់ ១១៨,១លានដុល្លារ ក្នុងនោះការនាំចេញកៅស៊ូមាន ៤៨,៣លានដុល្លារ, ការនាំចេញឈើ ១១,៦លានដុល្លារ, ការនាំចេញត្រី ០,២លានដុល្លារ, ការនាំចេញអង្ករ ៥៣,៤លានដុល្លារ, និងការនាំចេញផលិតផលកសិកម្មផ្សេងទៀត ៤,៦លានដុល្លារ។

នៅត្រីមាសទី៣ ដដែលនេះ ការនាំចូល ធ្លាក់ចុះ ៥០,៨% ធៀបត្រីមាសមុន ប៉ុន្តែកើន ៣,៨% ធៀបមួយឆ្នាំមុន ដល់ ៣០១៧,០លានដុល្លារ។ ការនាំចូលសាំង មានចំនួន ៩៣,៣លានដុល្លារ, ម៉ាស៊ូតមាន ១៧៣,៧លានដុល្លារ, សម្ភារសំណង់ ៨៣,១លានដុល្លារ, ការនាំចូលផ្សេងទៀត ២៦៦៧,០លានដុល្លារ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឆ្នាំ២០១៦ ចំណូលរដ្ឋាភិបាលសរុប ធ្លាក់ចុះ ១១,៣% ធៀបត្រីមាសមុន ដល់ ៣៤១៣,៧ប៊ីលានរៀល ក្នុងនោះ ចំណូលចរន្ត ធ្លាក់ចុះ ១២,០% ដល់ ៣៣៧៥,៩ប៊ីលានរៀល។ ចំណូលពន្ធ ធ្លាក់ចុះ ១៥,៤% ដល់ ២៨៥០,៥ប៊ីលានរៀល រីឯចំណូលមិនមែនពន្ធ កើន ១២,២% ធៀបត្រីមាសមុន ដល់ ៥២៥,៤ប៊ីលានរៀល។ ចំណាយសរុប កើន ១,៦% ធៀបត្រីមាសមុន ដល់ ៣៤៦០,៨ប៊ីលានរៀល ក្នុងនោះ ចំណាយមូលធន ធ្លាក់ចុះ ២៥,៦% ដល់ ៨១១,៣ប៊ីលានរៀល ប៉ុន្តែចំណាយចរន្ត កើន ១៤,៥% ដល់ ២៦៤៩,១ប៊ីលានរៀល។

អត្ថបទនេះ រៀបរាងដោយលោក វ៉េន សីហា ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវ ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថាន CDRI។

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០១៦ សន្ទស្សន៍ថ្លៃទំនិញសរុប មានកម្រិត ៣,០% គឺដូចគ្នានឹងត្រីមាសមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៥,៥% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៧,៩%។ ប្រាក់រៀល ចុះថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារ ដល់ ៤០៩៤,១/ដុល្លារ, ចុះថ្លៃ ២,១% ទល់នឹងប្រាក់បាតថៃ ដល់ ១១៨,១រៀល/បាត និង ចុះ ០,៨% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ ក្នុងពេលជាមួយគ្នា ម៉ាស៊ូតឡើងថ្លៃ ៤,០% ដល់ ៣០៥០,២រៀល/លីត្រ ប៉ុន្តែសាំងចុះថ្លៃ ១,១% ដល់ ៣២៨១,៤រៀល/លីត្រ ធៀបនឹងត្រីមាសមុន។

## ស្ថានភាពក្រីក្រ

នៅខែកញ្ញា ២០១៦ ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់ អ្នករត់ស៊ីក្លូ អ្នកលីសែង អ្នកស៊ីឈ្នួលធ្វើស្រែ និងអ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ធៀបនឹងកាលពីមួយឆ្នាំមុន រីឯចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ អ្នករត់តុភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងកម្មករសំណង់មានជំនាញ និង គ្មានជំនាញ កើនឡើង។

នៅខែកញ្ញា ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ៧,៥% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ៨២២៩រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ប្រមាណ ៦៣% ជាប្រភពចំណូលចម្បងសម្រាប់គ្រួសារខ្លួន ហើយ ៥០,០% ប្រាប់ថា គាត់រកចំណូលបានតិចជាងត្រីមាសមុន។ ពលករភាគច្រើនបញ្ជាក់ថា ចំណូលរបស់គាត់ក្នុងខែកញ្ញា អាចទ្រទ្រង់ជីវភាពគ្រួសារបានតែមួយភាគប៉ុណ្ណោះ។ ពលករប្រមាណ ៦៥% មានជាប់បំណុលគេ ហើយអត្រាការប្រាក់ជាមធ្យមលើការខ្ចីបុលនោះ គឺ ២,៤% ក្នុងមួយខែ។

ប្រាក់កម្រៃប្រចាំថ្ងៃរបស់កម្មករកាត់ដេរ ធ្លាក់ចុះ ១០,៩% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៣.១៣៦រៀល។ កម្មករ ប្រមាណ ៦៤% រៀបការរួច។ ពួកគាត់មានកម្រិតអប់រំជាមធ្យមត្រឹមថ្នាក់ទី៥។ ជាមធ្យម កម្មករទាំងនេះធ្វើការឲ្យរោងចក្របាន ៣,៦ឆ្នាំហើយ។ កម្មករប្រមាណ ៨១% ទទួលបានជំនាញពីការបណ្ដុះបណ្ដាលក្នុងរោងចក្រ ៣,៣% ពីការបណ្ដុះបណ្ដាលនៅផ្ទះ ហើយ ១៥,៩% ផ្សេងទៀតមិនមានជំនាញទេ។ ជាមធ្យម ពួកគាត់ធ្វើការ ៥៥,៤ម៉ោង/សប្ដាហ៍ និងសន្សំប្រាក់បានដល់ ៤៨,៣% នៃប្រាក់កម្រៃរបស់ខ្លួន។ កម្មករប្រមាណ ៨៩% ផ្ញើប្រាក់សន្សំទៅឲ្យក្រុមគ្រួសារ ហើយអាចជួយទ្រទ្រង់ជីវភាពគ្រួសារបានមួយភាគ។ កម្មករប្រមាណ ៦៦% មិនចង់ផ្លាស់ប្ដូរការងារទេ ហើយ ៧៦% មានសុទិដ្ឋិនិយមថា រោងចក្រគាត់នៅតែមានដំណើរការតទៅមុខទៀត។

នៅខែកញ្ញា ចំណូលរបស់អ្នកលក់បន្លែ កើន ៦,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៧.៤៨៨រៀល/ថ្ងៃ។ អ្នកលក់បន្លែទាំងនេះមកពី ខេត្តកណ្ដាល (៣៥%) ស្វាយរៀង (៣៥%) ព្រៃវែង (១០%) កំពង់ស្ពឺ (៥%) ក្រុងភ្នំពេញ (៥%) តាកែវ (៥%) កំពង់ចាម (២,៥%) និង កំពត (២,៥%)។ ពួកគាត់ប្រមាណ ៧៥% មានដីកសិកម្មពី ០,៣ ទៅ ១,៥ហិកតា ហើយ ២២,៥% គ្មានដីធ្លីទេ។ អ្នកឆ្លើយសម្ភាសន៍ប្រមាណ ៩៨% ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ ហើយ ៧៨% រាយការណ៍ថា មិនមានមូលធនគ្រប់គ្រាន់សម្រាប់បម្រើអាជីវកម្មរបស់ខ្លួនទេ។

ចំណូលរបស់អ្នករើសអេតចាយ កើន ០,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១១.៣៤៧រៀល/ថ្ងៃ។ ពួកគាត់ភាគច្រើនប្រាប់ថា ចំនួនអ្នករើសអេតចាយកើនឡើង ហើយ ប្រភពសម្រាម និងថ្លៃរបស់អេតចាយ បានថយចុះ។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ជាអ្នករកចំណូលចិញ្ចឹមគ្រួសារ ហើយត្រូវធ្វើការជាមធ្យម ១១,៦ម៉ោង/ថ្ងៃ។ ពួកគាត់ចាយអស់ ៣៩,៥% នៃចំណូលរកបាន ហើយភាគច្រើនទៅលើស្បៀងអាហារ (៧៣,៧% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១៥,១%) ការថែទាំសុខភាព (១,៨%) និងចំណាយផ្សេងទៀត (៩,៤%)។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ កើន ៣១,១% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ ១៩.១៧៤រៀល ហើយ ចំនួនរបស់ពួកគាត់ និងសកម្មភាពសាងសង់ បានកើនឡើង។ កម្មករ ៩៣% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ។ ជាមធ្យម ពួកគាត់ធ្វើការ ៩,៤ម៉ោង/ថ្ងៃ ហើយត្រូវចំណាយប្រាក់ភាគច្រើនទៅលើម្ហូបអាហារ។ ចំណូលរបស់ពួកគាត់អាចទ្រទ្រង់ជីវភាពគ្រួសារបានមួយភាគ។

ចំណូលរបស់អ្នកលីសែង ធ្លាក់ចុះ ៤,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន មកត្រឹម ១៣.៥១៤រៀល/ថ្ងៃ។ អ្នកលីសែង ៩៣% បានធ្វើចំណាកស្រុកតែម្នាក់ឯងមកក្រុងភ្នំពេញ ឬសៀមរាប ដើម្បីរកការងារធ្វើ។ ចំណូលរបស់ពួកគាត់ ត្រូវចាយវាយទៅលើ ម្ហូបអាហារ (៧៧,៤% នៃចំណាយសរុប) ថ្លៃឈ្នួលកន្លែងស្នាក់នៅ (១៥,៤%) ការថែទាំសុខភាព (០,៤%) និងចំណាយផ្សេងទៀត (៦,៧%)។ អ្នកឆ្លើយសម្ភាសន៍ ៧៥,០% ប្រាប់ថា តាំងពីចាប់ផ្ដើមធ្វើជាអ្នកលីសែងមក គ្រួសាររបស់គាត់មានជីវភាពប្រសើរជាងមុន ហើយ ២២,៥% ប្រាប់ថា គ្រួសារគាត់មានជីវភាពនៅដដែល។

ចំណូលប្រចាំថ្ងៃរបស់អ្នករត់តុភោជនីយដ្ឋាន កើន ៣,៦% ធៀបនឹងខែដូចគ្នា ឆ្នាំមុន ដល់ ៨០១៥រៀល។ អ្នកឆ្លើយសម្ភាសន៍គ្រប់គ្នា ទទួលបានកន្លែងស្នាក់នៅពីម្ចាស់ហាង។ ពួកគាត់ធ្វើការនេះបានប្រហែល ៣ឆ្នាំមកហើយ និងត្រូវបម្រើការក្នុងហាងជាមធ្យម ១០,៤ម៉ោង/ថ្ងៃ។ ពួកគាត់ចំណាយប្រាក់ចំណូលរបស់ខ្លួនអស់ ៦៦,៤% លើម្ហូបអាហារ ៥,៤% លើការថែទាំសុខភាព និង ១៥,៣% លើចំណាយផ្សេងៗទៀត។

# តាមដានសេដ្ឋកិច្ច - សូចនាករសេដ្ឋកិច្ច

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០១០-១៦*

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 530.7 | 725.0 | 531.6 | 930.5 | 56.5 | 25.8 | 38.1 | 79.1 | 26.8 | 27.6 | 0.0 | 7.4 |
| ឧស្សាហកម្ម | 403.7 | 2860.1 | 829.3 | 3257.0 | 1002.5 | 342.8 | 130.9 | 130.6 | 410.4 | 252.4 | 597.0 | 266.1 |
| *កាត់ដេរ* | 122.8 | 393.9 | 497.0 | 324.1 | 393.5 | 63.9 | 42.4 | 63.7 | 55.2 | 70.8 | 239.9 | 51.1 |
| សេវាកម្ម | 1337.3 | 3425.4 | 916.6 | 140.7 | 622.6 | 2504.6 | 85.6 | 69.7 | 74.5 | 643.6 | 234.1 | 681.9 |
| *សណ្ឋាគារ និងទេសចរណ៍* | 1105.1 | 2850.9 | 691.5 | 106.0 | 446.9 | 60.6 | 0.0 | 0.0 | 38.0 | 611.1 | 19.8 | 679.8 |
| សរុប | 2271.7 | 7010.4 | 2278.0 | 4328.0 | 1583.9 | 2873.2 | 254.6 | 279.4 | 511.7 | 923.7 | 831.2 | 955.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 1816.8 | -91.1 | 9.7 | 83.1 | 80.5 | -10.0 | 15.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -61.3 | 209.0 | -67.5 | 90.1 | 63.4 | 573.0 | -33.2 | -55.3 | 241.4 | -67.9 | 226.4 | 242.0 |

*Including expansion project approvals. Source: Cambodian Investment Board

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៩-១៥

| | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 | - | 637.6 |
| ផ្សេងៗ | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 | - | 252.6 |
| សរុប | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 | - | 897.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 | - | |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 | - | |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០១០-១៦

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1304.3 | 1480.4 | 1722.1 | 2017.7 | 2273.5 | 725.1 | 497.4 | 563.8 | 681.3 | 785.0 | 593.5 | 602.2 |
| តាមផ្លូវគោក និងទឹក | 1094.6 | 1401.4 | 1862.2 | 2192.5 | 2229.3 | 647.6 | 496.7 | 481.1 | 747.0 | 557.4 | 522,7 | 545.3 |
| សរុប | 2398.9 | 2881.8 | 3584.3 | 4210.2 | 4502.8 | 1372.6 | 994.2 | 1044.9 | 1428.4 | 1342.5 | 1116.2 | 1147.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | | 5.4 | -27.6 | 5.1 | 36.7 | -0.6 | -16.9 | 2.8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.6 | 20.1 | 24.4 | 17.5 | 7.0 | 8.3 | 6.5 | 4.6 | 9.6 | -2.4 | 12.3 | 9.8 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០១០-១៦ *

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3630.2 | 4929.5 | 6106.4 | 6982.4 | 8106.0 | 2170.1 | 2182.0 | 2595.0 | 2309.3 | 2388.3 | 2383.4 | 2817.7 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 3223.4 | 4259.6 | 5015.4 | 5386.1 | 5960.5 | 1548.8 | 1601.7 | 1995.3 | 1681.2 | 1759.4 | 1717.8 | 2072.5 |
| - *សហរដ្ឋអាមេរិក* | 1853.9 | 2055.3 | 2143.3 | 2075.2 | 1963.6 | 491.1 | 494.3 | 585.3 | 438.8 | 423.1 | 440.4 | 554.5 |
| - *សហភាពអឺរ៉ុប* | 809.5 | 1322.2 | 1716.9 | 1969.6 | 2403.7 | 617.3 | 685.9 | 844.1 | 756.6 | 789.6 | 776.6 | 733.4 |
| - *អាស៊ាន* | 9.9 | 17.6 | 39.4 | 60.2 | 83.3 | 24.8 | 24.6 | 26.4 | 27.5 | 25.6 | 25.7 | 21.4 |
| - *ជប៉ុន* | 86.5 | 147.0 | 188.6 | 278.7 | 383.1 | 121.4 | 93.6 | 170.8 | 138.4 | 176.0 | 122.5 | 216.0 |
| - *ប្រទេសផ្សេងៗ* | 463.6 | 717.5 | 927.2 | 1002.9 | 1126.8 | 294.2 | 303.4 | 368.8 | 319.9 | 345.2 | 352.7 | 547.1 |
| កសិកម្ម | 164.9 | 362.1 | 376.7 | 554.5 | 624.4 | 150.3 | 127.3 | 111.4 | 159.7 | 137.5 | 98.9 | 118.1 |
| - *កៅស៊ូ* | 89.1 | 197.6 | 176.6 | 175.2 | 153.9 | 41.7 | 40.9 | 42.1 | 40.7 | 30.7 | 26.8 | 48.3 |
| - *ឈើ* | 34.1 | 48.8 | 36.8 | 73.6 | 132.0 | 13.9 | 9.8 | 7.3 | 15.3 | 4.9 | 12.4 | 11.6 |
| - *ត្រី* | 2.8 | 3.1 | 2.0 | 1.2 | 0.8 | 0.2 | 0.2 | 0.1 | 0.1 | 0.2 | 0.1 | 0.2 |
| - *អង្ករ* | 34.7 | 106.6 | 146.4 | 262.3 | 248.5 | 89.5 | 72.4 | 54.7 | 98.8 | 91.4 | 56.1 | 53.4 |
| - *ផលិតផលកសិកម្មផ្សេងៗ* | 4.1 | 6.0 | 14.9 | 42.4 | 89.1 | 5.2 | 4.0 | 7.2 | 4.9 | 10.3 | 3.6 | 4.6 |
| ផ្សេងៗ | 242.0 | 307.9 | 714.4 | 1088.2 | 1520.1 | 471.0 | 452.9 | 488.0 | 468.4 | 491.3 | 566.6 | 627.1 |
| ការនាំចូលសរុប ក្នុងនេះ៖ | 5190.6 | 6375.9 | 8593.3 | 8639.4 | 10,295.4 | 2717.3 | 2920.3 | 2907.9 | 2949.1 | 2784.7 | 6136.6 | 3017.0 |
| សាំង | 108.6 | 294.4 | 308.0 | 306.4 | 334.7 | 34.5 | 92.2 | 96.5 | 65.1 | 95.4 | 99.2 | 93.31 |
| ម៉ាស៊ីន | 203.8 | 447.0 | 559.5 | 569.1 | 602.3 | 45.1 | 152.7 | 139.6 | 150.0 | 163.1 | 194.6 | 173.7 |
| សម្ភារសំណង់ | 57.6 | 48.1 | 66.1 | 80.8 | 117.6 | 12.4 | 42.0 | 45.9 | 42.1 | 50.8 | 62.1 | 83.05 |
| ផ្សេងៗ | 4820.6 | 5586.4 | 7659.1 | 7682.6 | 9240.7 | 835.2 | 2633.0 | 2626.0 | 2691.9 | 2475.0 | 5780.8 | 2667.0 |
| ជញ្ជីងពាណិជ្ជកម្ម | -1560.5 | -1446.4 | -1341.6 | -1610.9 | -2184.3 | -547.2 | -738.3 | -312.9 | -639.7 | -390.7 | -3753.3 | -199.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | 3.8 | 3.4 | 24.6 | -15.7 | 4.7 | -2.4 | 20,6 |
| ការនាំចេញសរុប | - | - | - | - | - | *1.5* | *0.5* | *18.9* | *-11.0* | *3.4* | *-0.2* | *18,2* |
| ការនាំចូលសរុប | - | - | - | - | - | -3.2 | 7.5 | -0.4 | 1.4 | -5.6 | 120.8 | -50,8 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 25.7 | 32.1 | 17.7 | 7.4 | 10.7 | 5.8 | 16.1 | 22.8 | 12.6 | 13.6 | 7.2 | 3,9 |
| ការនាំចេញសរុប | 25.1 | 35.8 | 23.9 | 14.3 | 16.1 | 9.8 | 17.3 | 21.7 | 8.1 | 10.1 | 9.2 | 8,6 |
| ការនាំចូលសរុប | 19.8 | 22.8 | 16.8 | 15.4 | 19.7 | 21.4 | 19.2 | 4.0 | 5.0 | 2.5 | 110.1 | 3,8 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (website)

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០១០-១៦ (ប៊ីលានរៀល)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 5989.0 | 6251.4 | 7691.9 | 8255.2 | 10,543.4 | 2647.8 | 3301.6 | 3063.8 | 2867.3 | 3533.1 | 3849.7 | 3413.7 |
| ចំណូលចរន្ត | 5859.1 | 6179.3 | 7443.8 | 8233.2 | 10,359.4 | 2638.0 | 3274.5 | 3028.7 | 2818.2 | 3514.7 | 3836.3 | 3375.9 |
| ចំណូលពន្ធ | 4693.0 | 5277.5 | 6334.8 | 7198.1 | 8995.2 | 2430.6 | 3006.1 | 2656.2 | 2409.7 | 3255.5 | 3368.1 | 2850.5 |
| ពន្ធក្នុងស្រុក | 3533.6 | 4071.6 | 5002.8 | 5728.1 | 7226.5 | 2012.6 | 2481.6 | 2153.9 | 1943.6 | 2715.3 | 2854.5 | 2378.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1159.4 | 1205.9 | 1331.7 | 1470.0 | 1822.7 | 418.0 | 524.5 | 502.3 | 466.1 | 540.1 | 513.6 | 472.0 |
| ចំណូលមិនមែនពន្ធ | 1166.1 | 901.8 | 1118.2 | 1035.2 | 1310.3 | 207.4 | 268.5 | 372.5 | 408.5 | 259.3 | 468.2 | 525.4 |
| ចំណូលលើទ្រព្យសម្បត្តិ | 291.1 | 63.8 | 143.0 | 84.0 | 88.5 | 3.0 | 16.7 | 35.9 | 21.7 | 8.1 | 26.1 | 43.2 |
| លក់ទំនិញ និងសេវា | 460.1 | 588.7 | 667.4 | 750.3 | 871.2 | 189.6 | 219.2 | 304.6 | 333.9 | 198.5 | 315.3 | 294.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 408.9 | 249.3 | 298.8 | 200.8 | 350.5 | 14.8 | 32.6 | 31.8 | 53.0 | 52.7 | 126.8 | 187.3 |
| ចំណូលជាមូលធន | 129.9 | 72.1 | 247.9 | 73.4 | 184.0 | 9.8 | 27.1 | 35.0 | 49.1 | 18.3 | 13.4 | 38.4 |
| ចំណាយសរុប | 8784.6 | 9032.4 | 9660.9 | 12,535.7 | 13,306.5 | 2093.3 | 1964.8 | 3337.5 | 5121.3 | 2364.3 | 3405.3 | 3460.8 |
| ចំណាយជាមូលធន | 2853.2 | 3546.9 | 3628.3 | 5567.5 | 5590.7 | 654.4 | 584.7 | 649.9 | 2083.4 | 620.9 | 1091.1 | 811.3 |
| ចំណាយចរន្ត | 4773.1 | 5341.2 | 6188.4 | 6968.3 | 7715.8 | 1438.9 | 1380.1 | 2687.7 | 3038.0 | 1743.4 | 2314.2 | 2649.1 |
| បៀវត្សរ៍ | 2048.8 | 2170.6 | 2486.6 | 2997.3 | 3755.5 | 945.3 | 959.1 | 1281.2 | 1086.3 | 1133.1 | 1418.3 | 1403.6 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 1099.4 | 1518.8 | 1586.8 | 1563.0 | 1627.0 | 194.3 | 207.1 | 544.0 | 797.1 | 259.1 | 439.7 | 447.5 |
| ចំណាយចរន្តផ្សេងទៀត | 1624.8 | 1651.8 | 2115.1 | 2408.0 | 2333.4 | 299.3 | 213.9 | 862.4 | 1154.6 | 351.2 | 456.2 | 798.1 |
| សមតុល្យជាទូទៅ | -2795.7 | -1271.4 | -1969.0 | -4280.6 | -2763.1 | 554.5 | 1336.8 | -273.8 | -2254.0 | 1168.8 | 444.4 | -47.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1845.2 | -2781.0 | 2457.8 | 4326.2 | 3972.1 | 368.9 | 330.1 | 297.6 | 1414.8 | 266.4 | 775.6 | 141.0 |
| ហិរញ្ញប្បទានក្នុងស្រុក | 938.6 | 2379.2 | -332.9 | 824.4 | -1428.7 | -2464.8 | -793.3 | -259.1 | -109.4 | -1631.4 | -488.5 | 37.5 |

Source: MEF website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០១០-១៦

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.1 | 5.4 | 2.3 | 3.0 | 3.9 | 1.0 | 1.0 | 0.8 | 2.0 | 2.5 | 3.0 | 3.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 4.4 | 6.5 | 2.5 | 3.9 | 4.9 | 4.2 | 3.9 | 3.3 | 4.7 | 4.7 | 6.2 | 5.5 |
| - ដឹកជញ្ជូន | 7.0 | 6.9 | 3.3 | -0.6 | -1.0 | -10.9 | -7.9 | -9.1 | -8.9 | -6.5 | -9.9 | -7.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4187.1 | 4063.6 | 4039.2 | 4036.2 | 4060.4 | 4042.2 | 4056.7 | 4091.8 | 4050.9 | 4022.4 | 4056.3 | 4094.1 |
| រៀលក្នុង ១ បាតថៃ | 133.1 | 133.2 | 130.0 | 124.9 | 119.4 | 124.4 | 122.6 | 116.8 | 113.6 | 113.4 | 115.7 | 118.1 |
| រៀលក្នុង ១០០ ដុងវៀតណាម | 21.7 | 19.7 | 19.4 | 19.1 | 18.7 | 19.0 | 18.8 | 18.6 | 18.2 | 18.1 | 18.3 | 18.5 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 147.5 | 184.5 | 200.9 | 175.9 | 152.3 | 150.9 | 144.4 | 136.0 | 130.9 | 151.2 | 151.2 | 157.1 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3859.3 | 4761.2 | 4941.2 | 4852.1 | 4934.1 | 3823.4 | 4032.0 | 3840.2 | 3389.4 | 2903.8 | 2932.8 | 3050.2 |
| ថ្លៃសាំង (រៀល/លីត្រ) | 4368.1 | 5044.5 | 5312.7 | 5083.3 | 5155.7 | 3986.2 | 4189.0 | 4048.9 | 3582.5 | 3310.6 | 3318.2 | 3281.4 |

Sources: NIS, NBC and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០១០-១៦ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2010 | 2011 | 2012 | 2013 | 2014 | 2015 | | | | 2016 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 16,697.9 | 17,893.9 | 18,154.5 | 21,260.1 | 26,699.7 | 26,823.0 | 27,975.3 | 26,359.2 | 26,665.5 | 29,247.8 | 30,138.5 | 32,188.4 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 2778.9 | 5760.8 | 10,437.4 | 11,508.3 | 15,859.8 | 16,863.2 | 18,178.3 | 20,600.9 | 22,157.6 | 21,643.0 | 24,399.1 | 24,939.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2126.6 | -2123.1 | -2486.4 | -2794.9 | -4359.1 | -5064.0 | -5666.1 | -5933.1 | -6428.8 | -7621.2 | -7977.4 | -7916.6 |
| ឥណទានដល់វិស័យឯកជន | 13,331.2 | 17,552.8 | 23,536.6 | 27,608.8 | 36,244.6 | 37,759.4 | 40,995.0 | 43,807.1 | 46,071.0 | 47,627.0 | 52,528.6 | 54,551.1 |
| រូបិយវត្ថុទូទៅ M2 | 19,476.8 | 23,654.7 | 28,591.9 | 32,768.4 | 42,559.5 | 43,685.2 | 46,153.7 | 46,960.1 | 48,823.1 | 50,890.9 | 54,537.6 | 57,127.5 |
| រូបិយវត្ថុ M1 | 3220.9 | 3956.2 | 4045.7 | 4878.2 | 6308.4 | 6628.0 | 6293.1 | 6287.5 | 6741.4 | 6717.8 | 6872.0 | 7460.9 |
| រូបិយវត្ថុផ្សេងៗ | | | | | | 37,058.2 | 39,860.6 | 40,672.6 | 42,081.7 | 44,173.1 | 47,665.6 | 49,666.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 20.0 | 17.8 | 20.9 | 14.6 | 29.9 | 24.2 | 20.6 | 15.2 | 14.7 | 16.5 | 18.2 | 21.7 |
| រូបិយវត្ថុ M1 | 3.2 | 16.9 | 2.3 | 20.6 | 29.3 | 23.3 | 20.3 | 12.6 | 6.9 | 1.4 | 9.2 | 18.7 |
| រូបិយវត្ថុផ្សេងៗ | 24.0 | 17.9 | 44.6 | 13.6 | 30.0 | 24.4 | 20.7 | 15.6 | 16.1 | 19.2 | 19.6 | 22.1 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ឆ្នាំ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2011 | 2012 | 2013 | 2014 | 2015** | 2016 | 2016 | | | 2016 | | |
| | | | | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នករត់ស៊ីក្លូ | 9532 | 10,303 | 10,438 | 10,774 | 12,405 | 11,880 | 11,898 | 11,302 | 10,985 | 1.9 | 1.9 | -44.0 |
| អ្នកលីសែង | 10,785 | 12,143 | 13,247 | 13,580 | 15,631 | 14,888 | 11,774 | 14,094 | 13,514 | -0.1 | 4.7 | -4.7 |
| អ្នកលក់បន្លែតូចតាច | 8337 | 10,771 | 11,366 | 14,751 | 15,867 | 20,337 | 18,979 | 11,903 | 17,488 | 11.5 | -5.7 | 6.1 |
| អ្នករើសអេតចាយ | 8388 | 8680 | 9819 | 9173 | 12,344 | 11,159 | 8737 | 9953 | 11,347 | -34.2 | -13.5 | 0.1 |
| អ្នករត់តុភោជនីយដ្ឋាន* | 5986 | 6111 | 6697 | 7789 | 8,436 | 7860 | 8187 | 7895 | 8,015 | -0.01 | 3.6 | 3.6 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5695 | 6151 | 6599 | 7514 | 8,745 | 8,484 | 7916 | 7722 | 8,229 | 4.8 | -16.8 | -7.5 |
| កម្មកររោងចក្រកាត់ដេរ | 8409 | 8932 | 10,161 | 11,178 | | 14,937 | 13,828 | 12,900 | 13,136 | -3.0 | -11.6 | -10.9 |
| អ្នករត់ម៉ូតូឌុប | 11,568 | 12,930 | 13,450 | 13,386 | 14,455 | 15,526 | 15,425 | 13,653 | 13,434 | 12.1 | 2.8 | -6.7 |
| កម្មករសំណង់គ្មានជំនាញ | 10,307 | 11,078 | 13,184 | 13,336 | 15,349 | 16,164 | 20,227 | 13,894 | 19,174 | 39.7 | 6.2 | 31.1 |
| កម្មករសំណង់មានជំនាញ | 13,159 | 13,743 | 15,442 | 17,420 | 18,624 | 18,853 | 21,150 | 19,184 | 20,287 | 13.4 | 7.9 | 13.8 |

* Waitresses/waiters’ earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. **November 2015 data are not available, so percentage changes in November 2016 were estimated.
Source: CDRI